# សាសនាចក្រតែមួយដែលពិតហើយសកម្ម

ប្រធាន ហ៊ិនរី ប៊ី អាវរិង
ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ

*សាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ទាំងពិត និងសកម្ម ។*

ពេលយើងគាំទ្រ ប្រធាន ថូម៉ាស អេស ម៉នសុន ជាព្យាការី អ្នកមើលឆុត និងអ្នកបើកសម្ដែង និងជាប្រធាននៃសាសនាចក្រ ព្រមទាំងលោក ឌី ធូឌ គ្រីស្ទហ្វឺសុន ជាសាវក និងជាសមាជិកនៃក្រុមសាវក 12 នាក់ យើងបានឃើញ និងទទួលនូវភស្តុតាងថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជាសាសនាចក្រទាំងពិត និងសកម្ម។ ព្រះអម្ចាស់នមានបន្ទូលចំពោះអ្នកទាំងឡាយ តាមរយៈអ្នកដែលទ្រង់បានស្ដារសាសនាចក្រឡើងវិញ នៅថ្ងៃចុងក្រោយនេះ។ ទ្រង់មានបន្ទូលអំពីពួកគេថាពួកគេ "អាចមានអំណាចដើម្បីកសាងគ្រឹះនៃសាសនាចក្រនេះ ហើយដើម្បីនាំសាសនាចក្រចេញពីទីអាប់អួរ និងពីទី នៃសេចក្ដីងងឹត គឺជាសាសនាចក្រតែមួយដែលពិត ហើយសកម្ម នៅលើផ្ទៃផែនដីទាំងមូល ដែលយើងជាព្រះអម្ចាស់សព្វព្រះហឫទ័យណាស់ ដោយនិយាយដល់សាសនាចក្រទាំងស្រុង ហើយមិនមែននីមួយៗទេ--- ត្បិតយើងជាព្រះអម្ចាស់ពុំអាចទតមើលអំពើបាបសូម្បីតែបន្តិចបន្តួចបានឡើយ ប៉ុន្ដែអ្នកណាដែលប្រែចិត្ត ហើយធ្វើតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ នោះនឹងបានអត់ទោស ហើយអ្នកណាដែលមិនប្រែចិត្ត នោះនឹងបានយកពីអ្នកនោះវិញ សូម្បីតែពន្លឺដែលគេបានទទួលក្តី ត្បិតវិញ្ញាណរបស់យើង ពុំតស៊ូគង់នៅជាមួយនឹងមនុស្សជានិច្ចទេ ព្រះអម្ចាស់នៃពួកពលបរិវារមានព្រះបន្ទូលថាដូច្នោះ" ។1

នេះគឺជាសាសនាចក្រពិត ជាសាសនាចក្រពិតតែមួយគត់ ដោយសារតែនៅក្នុងសាសនាចក្រមាននូវកូនសោទាំងឡាយនៃបព្វជិតភាព។ មានតែនៅក្នុងសាសនាចក្រនេះទេ ដែលព្រះអម្ចាស់បានដាក់ព្រះចេស្ដារដើម្បីភ្ជាប់នៅលើផែនដី និងភ្ជាប់នៅលើស្ថានសួគ៌ដូចដែលទ្រង់បានធ្វើនៅក្នុងជំនាន់របស់សាវកពេត្រុស។ កូនសោទាំងនោះត្រូវបានស្ដារឡើងវិញដល់លោកយ៉ូសែប ស្ម៊ីធ ដែលក្រោយមកត្រូវបានអនុញ្ញាតឱ្យប្រគល់កូនសោនោះមកដល់សមាជិកនៃក្រុមនៃពួកសាវក 12 នាក់។

នៅពេលព្យាការីយ៉ូសែប ត្រូវបានសំលាប់ សត្រូវរបស់សាសនាចក្រ បានគិតថាសាសនាចក្រនឹងផុតរលត់ទៅ។ ពួកគេគិតថាសាសនាចក្រគឺជាការបង្កើតឡើងដោយមនុស្សដែលរមែងស្លាប់ ហើយហេតុដូច្នេះសាសនាចក្រនឹងវិនាសទៅជាមួយនឹងលោក។ ប៉ុន្តែការសង្ឃឹមរបស់ពួកគេត្រូវបានសាបសូន្យ។ សាសនាចក្រនេះពិត ហើយមាននូវអំណាចដើម្បីបន្តដើរទៅមុខ សូម្បីតែនៅពេលដែលអ្នកទាំងឡាយ ដែលបានជ្រើសរើសឱ្យដឹកនាំក្នុងមួយគ្រាៗត្រូវបានទទួលមរណភាពទៅក្តី។

យើងបានមើលឃើញនៅសព្វថ្ងៃនេះនូវការបង្ហាញមួយ ដែលថានេះគឺជាសាសនាចក្រពិត និងសកម្ម។ កូនសោទាំងឡាយនៃបព្វជិតភាព ត្រូវបានកាន់ដោយមនុស្សរមែងស្លាប់ ប៉ុន្តែផ្លូវត្រូវបានរៀបចំឡើងដោយព្រះអម្ចាស់ ដើម្បីឱ្យកូនសោទាំងឡាយនៅតែបន្តរដំណើរការនៅលើផែនដី ដរាបណាមនុស្សអនុវត្តសេចក្ដីជំនឿ ទាំងកូនសោទាំងឡាយ

ដែលនៅលើផែនដី និងអ្នកទាំងឡាយដែលបានទទួលមរណភាពទៅ តាមព្រះទ័យរបស់ព្រះចំពោះអ្នកបំរើដែលបានជ្រើសរើសរបស់ទ្រង់។

វាស្រួលរបស់ព្រះមិនតែងតែមានភាពសក្តិសមចំពោះបទពិសោធន៍ដ៏អស្ចារ្យ ដែលយើងបានចែកចាយនៅថ្ងៃនេះទេ។ ពួកសាវកបន្ទាប់ពីការយាងឡើងទៅស្ថានសួគ៌វិញរបស់ព្រះគ្រីស្ទ បន្តអនុវត្តកូនសោ ដែលទ្រង់បានទុកឱ្យពួកគេ។ ប៉ុន្តែដោយសារតែការមិនគោរពតាម និងបាត់បង់សេចក្តីជំនឿរបស់សមាជិក ពួកសាវកបានស្លាប់ដោយគ្មានប្រគល់បានកូនសោទៅឱ្យពួកអ្នកស្នងឡើយ។ យើងហៅព្រឹត្តិការណ៍ដ៏អាក្រក់នោះថា "ការក្បត់សាសនា"។ បើសមាជិកនៃសាសនាចក្រនៅក្នុងសម័យនោះមានឱកាស និងឆន្ទៈដើម្បីអនុវត្តសេចក្តីជំនឿ ដូចអ្នករាល់គ្នាមាននៅសព្វថ្ងៃនេះ នោះព្រះអម្ចាស់នឹងមិនដកយកកូនសោនៃបព្វជិតភាពពីផែនដីនោះទេ។ ដូច្នេះនេះគឺជាជំនាន់ដ៏សំខាន់ជាប្រវត្តិសាស្ត្រ និងសំខាន់ដ៏នៅអស់កល្បជានិច្ច នៅក្នុងប្រវត្តិសាស្ត្ររបស់ពិភពលោក និង សំខាន់ដ៏នៅអស់កល្បជានិច្ចចំពោះកូនចៅរបស់ព្រះវរបិតាសួគ៌របស់យើង។

ឥឡូវ កាតព្វកិច្ចរបស់យើងគឺត្រូវនៅមានភាពសក្តិសមនៃសេចក្តីជំនឿ ដែលចាំបាច់ដើម្បីយើងបំពេញតាមសេចក្តីសន្យា ដើម្បីគាំទ្រដល់អ្នកទាំងឡាយដែលត្រូវបានហៅ។ ព្រះអម្ចាស់សព្វព្រះទ័យនឹងសាសនាចក្រកាលពីចាប់ផ្តើមការស្តារឡើងវិញ ដូចគ្នានឹងនៅសព្វថ្ងៃនេះផងដែរ។ ប៉ុន្តែទ្រង់បានដាស់តឿនសមាជិកកាលពីពេលនោះក៏ដូចគ្នានឹងពេលនេះដែរថា ទ្រង់ពុំអាចទតមើលអំពើបាបសូម្បីតែបន្តិចបន្តួចបានឡើយ។ ចំពោះយើងដើម្បីគាំទ្រដល់អ្នកទាំងឡាយដែលត្រូវបានហៅនៅថ្ងៃនេះ យើងត្រូវតែត្រួតពិនិត្យមើលជីវិតរស់នៅរបស់យើង ប្រែចិត្តជាចាំបាច់ សន្យាថា រក្សាបទបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ និងធ្វើតាមអ្នកបំរើរបស់ទ្រង់។ ព្រះអម្ចាស់ព្រមានយើងថា បើយើងមិនធ្វើនូវរឿងទាំងនេះទេ នោះព្រះវិញ្ញាណបរិសុទ្ធនឹងដកចេញពីយើង យើងនឹងបាត់បង់ពន្លឺដែលយើងបានទទួល ហើយយើងនឹងមិនអាចរក្សាការសន្យាដែលយើងបានធ្វើនៅថ្ងៃនេះ ដើម្បីគាំទ្រដល់អ្នកបំរើរបស់ព្រះអម្ចាស់នៅក្នុងសាសនាចក្រពិតរបស់ទ្រង់ទេ។

យើងម្នាក់ៗត្រូវតែធ្វើការវាយតម្លៃខ្លួនយើង។ ដំបូង យើងត្រូវការវាស់មើលជំរៅនៃការដឹងគុណរបស់យើងចំពោះសមាជិកភាពនៅក្នុងសាសនាចក្រពិតនៃព្រះយេស៊ូវគ្រីស្ទ។ ទីពីរ យើងចាំបាច់ត្រូវដឹង ដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ថាតាមរបៀបណាដែលយើងអាចធ្វើឱ្យបានល្អប្រសើរជាង ក្នុងការគោរពតាមបទបញ្ញត្តិទាំងឡាយ។

យើងដឹងមកពីការព្យាករណ៍ ដែលថាសាសនាចក្រពិត និងសកម្ម នឹងមិនត្រូវដកយកចេញពីផែនដីម្តងទៀតទេ ប៉ុន្តែ សាសនាចក្រនឹងប្រែក្លាយកាន់តែល្អឡើង។ ជីវិតរបស់យើងនឹងផ្លាស់ប្រែកាន់តែប្រសើរ នៅពេលយើងអនុវត្តសេចក្តីជំនឿទៅរកការប្រែចិត្ត តែងតែចងចាំព្រះអង្គសង្គ្រោះជានិច្ច ហើយព្យាយាមកាន់តែខ្លាំងឡើងដើម្បីរក្សាបទបញ្ញត្តិរបស់ទ្រង់។ បទគម្ពីរមាននូវការសន្យាទាំងឡាយថា នៅពេលព្រះអម្ចាស់យាងមកម្តងទៀតក្នុងសាសនាចក្ររបស់ទ្រង់ ទ្រង់នឹងរកឃើញថាសាសនាចក្រត្រូវបានរៀបចំខ្លួនខាងវិញ្ញាណដើម្បីទទួលទ្រង់។ រឿងនោះគួរតែធ្វើឱ្យយើងមានទាំងការប្តេជ្ញាចិត្ត និងសុទិដ្ឋិនិយម។ យើងត្រូវតែធ្វើឱ្យបានកាន់តែល្អប្រសើរ។ យើងអាចធ្វើបាន។ ហើយយើងនឹងធ្វើបាន។

នៅក្នុងថ្ងៃពិសេសនេះ វាគឺជាភាពវៃឆ្លាតដើម្បីប្ដេជ្ញាចិត្តគាំទ្រជាមួយនឹងសេចក្ដីជំនឿរបស់យើង និងការអធិស្ឋានរបស់យើងចំពោះអ្នកទាំងឡាយណា ដែលបំរើដល់យើងនៅក្នុងនគរ។ រូបខ្ញុំផ្ទាល់បានដឹងអំពីអំណាចនៃសេចក្ដីជំនឿរបស់សមាជិកនៃសាសនាចក្រ ដើម្បីគាំទ្រដល់អ្នកទាំងឡាយដែលត្រូវបានហៅ។ កាលពីប៉ុន្មានសប្ដាហ៍មុន ខ្ញុំបានទទួលអារម្មណ៍ដែលប្រកបដោយអានុភាពនៃការអធិស្ឋាន និងសេចក្ដីជំនឿរបស់មនុស្សដែលខ្ញុំមិនដែលស្គាល់ ហើយដែលគេស្គាល់ខ្ញុំគ្រាន់តែជាមនុស្សម្នាក់ ដែលបានហៅឱ្យបំរើតាមរយៈកូនសោនៃបព្វជិតភាព។ ប្រធានថូម៉ាស អេស ម៉នសុននឹងត្រូវបានប្រទានពរដោយការគាំទ្រដោយក្ដីជំនឿរបស់អ្នក។ គ្រួសាររបស់លោកក៏ដូច្នោះដែរ នឹងមានពរជ័យចាក់ស្រោចមកលើពួកគេ ដោយសារតែសេចក្ដីជំនឿរបស់អ្នក និងការអធិស្ឋានរបស់អ្នក។ អ្នកទាំងអស់ណាដែលត្រូវបានគាំទ្រដោយអ្នករាល់គ្នានៅថ្ងៃនេះ នឹងត្រូវបានគាំទ្រដោយព្រះអម្ចាស់ ដោយសារតែសេចក្ដីជំនឿរបស់ពួកគេ និងអ្នក។

សមាជិកគ្រប់រូបនឹងមានឱកាសច្រើនដើម្បីគាំទ្រតាមរយៈការបំរើ ដែលត្រូវបានប្រគល់ឱ្យនៅក្នុងព្រះនាមរបស់ព្រះ។ សាសនាចក្រនេះ គឺជាកម្លាំងដែលប្រកបដោយថាមពលមួយសំរាប់ជាពរជ័យដល់សមាជិក និងមនុស្សទាំងអស់នៅលើផែនដី។ ជាឧទាហរណ៍ សាសនាចក្របានធ្វើកិច្ចការសប្បុរសធម៌ដ៏អស្ចារ្យនៅទូទាំងផែនដី។ កិច្ចការទាំងអស់នោះសំរេចទៅបានដោយសារតែសេចក្ដីជំនឿរបស់សមាជិក និងមិត្តភក្ដិថាព្រះមានព្រះជន្មរស់ ហើយថាព្រះសព្វព្រះទ័យចង់ឱ្យ ជួយដល់អ្នកទាំងឡាយដែលខ្វះខាត ដែលទ្រង់អាចឈោងទៅរកតាមរយៈពួកសិស្សដ៏ស្មោះត្រង់ទាំងឡាយរបស់ទ្រង់។

បន្ថែមពីលើនេះទៀត តាមរយៈសាសនាចក្រនេះ និងពិធីបរិសុទ្ធទាំងឡាយ ដែលមាននៅក្នុងសាសនាចក្របានឱ្យពរជ័យទាំងឡាយនៃអំណាចផ្សារភ្ជាប់ បានឈោងទៅដល់ពិភពវិញ្ញាណ។ នេះគឺជាសាសនាចក្រពិត និងសកម្មដែលឈោងទៅរកសូម្បីតែអ្នកទាំងឡាយណាដែលបានទទួលមរណភាពទៅហើយក្ដី។ នៅពេលអ្នកមានសេចក្ដីជំនឿដើម្បីស្វែងរកឈ្មោះរបស់ជីដូនជីតារបស់អ្នក នៅពេលអ្នកទៅក្នុងដំណាក់របស់ព្រះអម្ចាស់ ដើម្បីផ្ដល់ដល់ពួកគាត់នូវពិធីបរិសុទ្ធជំនួស នោះអ្នកគាំទ្រដល់កិច្ចការដ៏មហិមានេះ ដែលមានគោលបំណងដើម្បីផ្ដល់សេចក្ដីសង្គ្រោះដល់កូនចៅរបស់ព្រះវរបិតាសួគ៌ទាំងអស់ ដែលចូលមកក្នុងពិភពលោកនេះ។

ខ្ញុំចង់និយាយអំពីមូលហេតុ ដែលខ្ញុំមើលឃើញថាហេតុអ្វីយើងគួរមានអំណរគុណ ចំពោះសាសនាចក្រពិត និងសកម្ម។ បន្ទាប់មកខ្ញុំនឹងឱ្យយោបល់នូវរបៀបមួយចំនួន ដែលខ្ញុំមើលឃើញថា សាសនាចក្រកំពុងត្រូវបានរៀបចំសំរាប់ការយាងមករបស់ព្រះអង្គសង្គ្រោះ។ ហើយនៅទីបញ្ចប់ ខ្ញុំនឹងថ្លែងទីបន្ទាល់របស់ខ្ញុំ អំពីរបៀបដែលខ្ញុំបានដឹងថានេះគឺជា សាសនាចក្រពិត និងសកម្ម។

លើសពីនោះខ្ញុំមានអំណរគុណចំពោះបទពិសោធន៍របស់ខ្ញុំ អំពីព្រះចេស្ដារលាងសំអាត ដែលមានតាមរយៈពិធីបរិសុទ្ធទាំងឡាយ ដែលបានធ្វើឡើងដោយអំណាចនៃបព្វជិតភាព។ ខ្ញុំបានទទួលអារម្មណ៍អភ័យទោស និងស្អាតតាមរយៈពិធីបុណ្យជ្រមុជទឹកដោយអ្នកទាំងឡាយដែលមានសិទ្ធិអំណាច។ ខ្ញុំបានទទួលអារម្មណ៍ខ្វល់ខ្វាញ់ខាងក្នុងខ្លួនដែលអាចមានតែតាមពាក្យទាំងឡាយ ដែលបាននិយាយដោយអ្នកបំរើរបស់ព្រះប៉ុណ្ណោះថា "ចូរទទួលព្រះវិញ្ញាណបរិសុទ្ធចុះ" ។

អារម្មណ៍នៃការដឹងគុណរបស់ខ្ញុំ ចេញមកពីពរជ័យទាំងឡាយដែលមានចំពោះគ្រួសារខ្ញុំផងដែរ។ វាគឺជាអំណាចផ្សារភ្ជាប់ និងចំណេះដឹងរបស់យើងអំពីអំណាចនោះ ដែលផ្លាស់ប្ដូរ និងផ្លាស់ប្រែជីវិតក្រុមគ្រួសាររបស់យើងនៅទីនេះ

និងការរំពឹងទុកនូវសេចក្ដីអំណររបស់យើងនៃជីវិតគ្រួសារដល់បរលោកនាយ ។ គំនិត និងសេចក្ដីសង្ឃឹម ដើម្បីខ្ញុំអាចមានទំនាក់ទំនងដ៏នៅអស់កល្បជានិច្ច បានជួយខ្ញុំឱ្យឆ្លងកាត់ឧបសគ្គនៃការបែកគ្នា និងភាពឯកកោដែលជាចំណែកនៃជីវិតរមែងស្លាប់ ។ ការសន្យាចំពោះអ្នកស្មោះត្រង់នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺថាយើងអាចមានទំនាក់ទំនង និងការពង្រីកនៃក្រុមគ្រួសារនៅក្នុងភាពដ៏នៅអស់កល្បជានិច្ច ។ ការអះអាងនោះផ្លាស់ប្ដូរនូវទំនាក់ទំនងរបស់យើងទាំងអស់គ្នា នៅក្នុងក្រុមគ្រួសារជារៀងរហូត និងកាន់តែល្អប្រសើរឡើង ។

ជាឧទាហរណ៍ ខ្ញុំស្ថិតនៅក្នុងដំណាក់កាលមួយនៃជីវិតរបស់ខ្ញុំ ពេលដែលមានគំលាតយ៉ាងខ្លាំង ដែលខ្ញុំមិនអាចស្គាល់ចៅ និងចៅតួតឱ្យបានច្បាស់ ។ ក៏មានមនុស្សជាច្រើនដែលគ្មានឱកាសដើម្បីរៀបការ ហើយធ្វើជាឪពុកម្ដាយដែលមានការចង់បានដូចគ្នានឹងខ្ញុំ ដើម្បីឱ្យមានភាពជិតស្និតនឹងគ្រួសារ ។ ដោយសារតែការស្ដារឡើងវិញនៃចំណេះដឹងអំពីក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ច យើងកាន់តែមានសង្ឃឹម និងចិត្តល្អនៅក្នុងទំនាក់ទំនងក្រុមគ្រួសាររបស់យើងទាំងអស់ ។ សេចក្ដីអំណរដ៏ធំបំផុតនៅក្នុងជីវិតនេះផ្ដោតសំខាន់ទៅលើក្រុមគ្រួសារ ក៏ដូចជានៅឯបរលោកនាយផងដែរ ។ ខ្ញុំមានអំណរគុណខ្លាំងណាស់ចំពោះការអះអាងដែលខ្ញុំមានថា បើយើងស្មោះត្រង់ ទំនាក់ទំនងដូចគ្នានេះដែលយើងរីករាយនៅក្នុងជីវិតនេះ នឹងមានជារៀងរហូតជាមួយយើងនៅក្នុងបរលោកនាយ នៅក្នុងសិរីល្អដ៏នៅអស់កល្បជានិច្ច ។2

ខ្ញុំអាចមើលឃើញភស្តុតាងនៃការធ្វើឱ្យសាសនាចក្របានល្អឥតខ្ចោះដែលបានព្យាករទុក ។ ជាឧទាហរណ៍ នៅពេលខ្ញុំធ្វើដំណើរ ហើយស្គាល់សមាជិកនៃសាសនាចក្រ ខ្ញុំមើលឃើញថាមានការរីកចំរើនយ៉ាងខ្ជាប់ខ្ជួនមួយនៅក្នុងជីវិតរស់នៅរបស់ពួកគេ ។ នៅក្នុងសេចក្ដីជំនឿ និងការគោរពប្រណិបត្តិដ៏សាមញ្ញរបស់ពួកគេ ដង្វាយធួនកំពុងតែផ្លាស់ប្ដូរ និងស្អាងដល់សមាជិកទាំងឡាយ ។ ជារឿយៗ ខ្ញុំនៅក្នុងការប្រជុំជាមួយនឹងមនុស្សរាបសារ ដែលត្រូវបានអនុញ្ញាតឱ្យបង្រៀនមេរៀន និងផ្ដល់ទេសនាកថា ដែលមានក្នុងមេរៀននូវអំណាចដូចដែលបានប្រគល់ដល់លីហៃ និងនីហ្វៃជាកូនប្រុសរបស់ហេលេមិន ។ អ្នកចងចាំអំពីដំណើររឿងថា:

"ហើយហេតុការណ៍បានកើតឡើងថា នីហ្វៃ និងលីហៃបានផ្សាយដល់ពួកសាសន៍លេមិនដោយអានុភាព និងសិទ្ធិអំណាចដ៏ខ្លាំង ព្រោះពួកគេមានអានុភាព និងសិទ្ធិអំណាចដែលបានប្រទានដល់គេ ដើម្បីឱ្យគេអាចនិយាយហើយពួកគេក៏មានដែរនូវអ្វីៗដែលពួកគេត្រូវនិយាយដែលបានប្រទានដល់គេ" ។3

ខ្ញុំមានទំនុកចិត្តថាការចង់បានដដែលៗរបស់ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី និងត្រូវបានទទួល ។ លោកបានបង្រៀនថា អស់អ្នកណាដែលចូលមកក្នុងសាសនាចក្រ អាចត្រូវបានថែរក្សានៅក្នុងការរាប់អានពេញលេញ បើពួកគេត្រូវបានចិញ្ចឹមបីបាច់ដោយព្រះបន្ទូលដ៏ល្អនៃព្រះ ។ ខ្ញុំចងចាំពាក្យរបស់លោកដែលជាពាក្យចុងក្រោយ ដែលលោកបាននិយាយនៅទីបញ្ចប់នៃការបំរើរបស់លោកគឺពាក្យថា "ថែរក្សា ថែរក្សា ថែរក្សា" ។ ពាក្យរបស់លោកនៅរស់រាននៅក្នុងភាពជាអ្នកដឹកនាំរបស់ប្រធាន ម៉នសុន និងនៅក្នុងយើងទាំងអស់គ្នា នៅពេលយើងសក្ដិសមដើម្បីមានអានុភាពរបស់លីហៃ និងនីហ្វៃ ដើម្បីចិញ្ចឹមបីបាច់ដោយព្រះបន្ទូលដ៏ល្អនៃព្រះ ។ ខ្ញុំមានទំនុកចិត្តថា អ្នកនឹងបន្ត ក៏ដូចជាខ្ញុំផងដែរ បន្តដើម្បីទទួលភាពអស្ចារ្យ ដោយពួកបរិសុទ្ធថ្ងៃចុងក្រោយរាបសារ ដែលបង្រៀនតាមផ្ទះ សួរសុខទុក្ខតាមផ្ទះ និងនិយាយទៅកាន់មិត្តភក្ដិរបស់ពួកគេដែលមិនមែនជាសមាជិក ដោយអានុភាពដ៏អស្ចារ្យបន្ថែមទៀត ។

អស់រយៈពេលជាច្រើនឆ្នាំ យើងបានចងចាំពាក្យរបស់ប្រធាន ដាវីឌ អូ មិកឃេ "សមាជិកគ្រប់រូបគឺជាអ្នកផ្សព្វផ្សាយសាសនា" ។ ខ្ញុំមានទំនុកចិត្តថា ពេលនោះបានមកដល់ហើយ ថាតាមរយៈសេចក្ដីជំនឿរបស់សមាជិក

នោះយើងនឹងមើលឃើញនូវចំនួនមនុស្សដែលបានអញ្ជើញឱ្យស្ដាប់ ព្រះបន្ទូលដ៏ល្អនៃព្រះកើនឡើង ហើយដែលបន្ទាប់មកនឹងចូលមកក្នុងសាសនាចក្រពិត និងសកម្ម ។

មានការរីកចំរើនផ្សេងទៀត ដែលខ្ញុំមានទំនុកចិត្តថានឹងកើតឡើង ។ ក្រុមគ្រួសារនៅទូទាំងសាសនាចក្រកំពុងតែស្រាវជ្រាវរកមធ្យោបាយដើម្បីពង្រឹង និងការពារដល់កូនចៅរបស់ពួកគេពីសេចក្ដីអាក្រក់ដែលនៅជុំវិញពួកគេ ។ នៅក្នុងករណីខ្លះ ឪពុកម្ដាយទាំងនោះ បានព្យាយាមទាំងអស់សង្ឃឹម ដើម្បីនាំគ្រួសាររបស់ពួកគេមួយចំនួនដែលបានវង្វេងឱ្យត្រឡប់មកវិញ ។ ខ្ញុំមានទំនុកចិត្តថានឹងមានរង្វាន់មួយត្រូវបានប្រទានឱ្យដោយព្រះចំពោះការខិតខំ របស់ពួកគេដែលបានបង្កើនឡើងនោះ ។ អ្នកទាំងឡាយណាមិនដែលបោះបង់ការព្យាយាម នឹងមើលឃើញថាព្រះក៏មិនដែលបោះបង់ចោលដែរ ហើយថាទ្រង់នឹងជួយពួកគេ ។

ជំនួយជាច្រើននោះនឹងមានមកពីអ្នកទាំងឡាយណាដែលត្រូវបានហៅឱ្យបំរើនៅក្នុងសាសនាចក្រ ។ បំណងប្រាថ្នានៃការឈោងទៅជួយនឹងបង្កើនឡើង ដើម្បីឱ្យមានមនុស្សជាច្រើនដូចជាប៊ីស្សព ថូម៉ាស ម៉នសុន វ័យក្មេង ដែលបានបំផុសគំនិតនៅក្នុងរបៀបដ៏ប្រសប់ ដើម្បីអញ្ជើញ និងលើកទឹកចិត្តដល់អ្នកទាំងឡាយ ដែលមិនបានស្គាល់ពរជ័យរបស់ព្រះរក្សាទុកឱ្យពួកគេសំរាប់ពេលនេះ ។ ប្រធាន ម៉នសុន មកដល់ថ្ងៃនេះ ចងចាំអំពីមនុស្សដែលលោកបានធ្វើការដើម្បីជួយសង្គ្រោះ នៅពេលលោកជាប៊ីស្សពរបស់ពួកគេ ។ សេចក្ដីសង្ឃឹមរបស់ខ្ញុំ គឺថាយើងទាំងអស់គ្នានឹងមានទំនុកចិត្តថា ព្រះនឹងដឹកនាំយើងឱ្យឈោងទៅរក និងនាំអ្នកទាំងឡាយដែលព្រះសព្វព្រះទ័យចង់ឱ្យយើងនាំគេមក នៅពេលយើងត្រឡប់ទៅផ្ទះចំពោះទ្រង់វិញ ។

ការរីកចំរើនមួយទៀត ដែលខ្ញុំមើលឃើញនាំចូលមកក្នុងនគរ គឺជាបំណងប្រាថ្នា និងសមត្ថភាពដើម្បីឈោងទៅជួយជនក្រីក្រ និងខ្វះខាត ។ ខ្ញុំបានមើលឃើញការរីកចំរើនដ៏អស្ចារ្យនូវការអាណិតអាសូរ នៅក្នុងចំណោមសមាជិកនៃសាសនាចក្រ ចំពោះជនរងទុក្ខដោយគ្រោះថ្នាក់ធម្មជាតិនៅជុំវិញពិភពលោក ។ នៅក្នុងការផ្សាយអំពីដំណឹងមរណភាពក្នុងកាសែត ខ្ញុំមើលឃើញក្រុមគ្រួសារជាច្រើនបានសុំបរិច្ចាគ ដល់មូលនិធិអប់រំដែលមានជាបន្តបន្ទាប់ ឬដល់មូលនិធិសប្បុរសធម៌របស់សាសនាចក្រ ។

ព្យាការីយ៉ូសែប ស្ម៊ីធ បានមើលឃើញនូវការរីកចំរើនដ៏អស្ចារ្យនោះ ។ លោកបានមានប្រសាសន៍ថា ក្នុងនាមជាមនុស្សម្នាក់ ដែលបានផ្លាស់ប្រែចិត្តជឿដោយពិតប្រាកដ គាត់ ឬនាង នឹងចង់ធ្វើដំណើរទៅគ្រប់ទីកន្លែងនៅលើផែនដីដើម្បីមើលថែដល់កូនចៅរបស់ព្រះវរបិតាសួគ៌ ។ រឿងនោះកំពុងតែចាប់ផ្ដើមកើតមាននៅក្នុងចំណោមសមាជិកនៃសាសនាចក្រជាច្រើនរួចហើយ ។ នោះជាការអស្ចារ្យណាស់ចំពោះខ្ញុំ ថាគំរូនៃការផ្ដល់ឱ្យទៅអ្នកទាំងឡាយដែលខ្វះខាតបានសន្ទឹងទៅកាន់អ្នកទាំងឡាយដែលមានតែបន្តិចបន្តួច ហើយការផ្ដល់ឱ្យនោះហាក់ដូចជាគ្មានរងឥទ្ធិពលអ្វីសោះទោះជាយើងស្ថិតនៅក្នុងគ្រាដែលសេដ្ឋកិច្ចល្អ ឬអាក្រក់ក្ដី ។ នេះគឺជាភស្តុតាងចំពោះខ្ញុំថា ដង្វាយធួនកំពុងតែធ្វើការកាន់តែមានប្រសិទ្ធភាពនៅក្នុងចំណោមសមាជិក ។

ទីបន្ទាល់របស់ខ្ញុំបានចាប់ផ្ដើមតាំងពីកុមារភាពរបស់ខ្ញុំមកម្ល៉េះថា នេះគឺជាសាសនាចក្រពិត និងសកម្ម ។ ការចងចាំដំបូងរបស់ខ្ញុំ ដែលខ្ញុំចាំគឺអំពីការប្រជុំសន្និសីទទូទៅ ដែលបានមិនធ្វើឡើងនៅក្នុងទីកន្លែងដូចនេះ ប៉ុន្តែនៅក្នុងបន្ទប់ជួលក្នុងសណ្ឋាគារមួយ ។ មានបុរសម្នាក់កំពុងតែនិយាយ ដែលខ្ញុំមិនស្គាល់គាត់ ថែមទាំងមិនស្គាល់ឈ្មោះគាត់ទៀតរហូតមកដល់សព្វថ្ងៃនេះ ។ ខ្ញុំគ្រាន់តែដឹងថាគាត់គឺជាមនុស្សម្នាក់ ដែលបានបញ្ជូនឱ្យទៅកាន់មណ្ឌលតូចរបស់យើង

នៅក្នុងតំបន់បេសកកម្ម ដោយមនុស្សម្នាក់ដែលកាន់បព្វជិតភាព។ ខ្ញុំមិនដឹងថាគាត់បាននិយាយអ្វីខ្លះទេ។ ប៉ុន្តែខ្ញុំបានទទួលនូវសាក្សីជាក់លាក់មួយប្រកបដោយអានុភាព មុនពេលខ្ញុំមានអាយុប្រាំបីឆ្នាំ មុនពេលខ្ញុំទទួលបុណ្យជ្រមុជទឹក ថាខ្ញុំបានស្ដាប់អ្នកបំរើរបស់ព្រះ នៅក្នុងសាសនាចក្រពិតនៃព្រះយេស៊ូវគ្រីស្ទ។ ទីបន្ទាល់នោះមិនមែនជាបន្ទប់ដួល ឬទំហំក្រុមជំនុំដែលតូចនោះទេ ប៉ុន្តែវាគឺជាសាក្សីមួយដែលខ្ញុំបានទទួលពរជ័យ នៅពេលដែលមានវត្តមាននៅក្នុងការប្រជុំអំពីសាសនាចក្រពិត។

នៅពេលខ្ញុំផ្លាស់ទៅជាមួយនឹងគ្រួសាររបស់ខ្ញុំ ដើម្បីទៅកន្លែងដែលបានរៀបចំស្តេកនៃសាសនាចក្រ ខ្ញុំមានអាយុជំទង់ តាំងពីពេលដំបូង ខ្ញុំបានទទួលអារម្មណ៍អំណាចនៃក្រុមបព្វជិតភាព និងនៃប៊ីស្សពជាទីស្រឡាញ់។ ខ្ញុំនៅចាំហើយអាចដឹងនូវការអះអាងដែលបានមានមក នៅពេលខ្ញុំអង្គុយនៅក្នុងក្រុមសង្ឃជិតនឹងប៊ីស្សព ហើយបានដឹងថាគាត់មានកូនសោនៃចៅក្រមដ៏ពិតនៅក្នុងអ៊ីស្រាអែល។

ចំពោះទីបន្ទាល់ដូចគ្នានោះកើតមានមកជាប់ពីរសប្តាហ៍ ទីបន្ទាល់មួយនៅក្នុង អាល់ប៊ីយូគើករដ្ឋ ញ៉ូមិចស៊ីកូ និងមួយទៀតនៅក្នុង បូស្តុន រដ្ឋ ម៉ាស្សាឈូសេត។ នៅក្នុងករណីនីមួយៗ ខ្ញុំត្រូវមានវត្តមាននៅក្នុងថ្ងៃដែលស្តេកមួយត្រូវបានរៀបចំ ឡើងចេញពីមណ្ឌល។ ដែលហាក់ដូចជា ពួកបុរសដែលខ្ញុំស្គាល់ច្បាស់ត្រូវបានហៅជាប្រធានស្តេក។ ខ្ញុំបានលើកដៃនៅក្នុងថ្ងៃទាំងនោះ ដូចដែលអ្នកបានធ្វើនៅក្នុងថ្ងៃនេះ ហើយសាក្សីមួយបានមានចំពោះខ្ញុំថា ព្រះបានហៅអ្នកបំរើរបស់ទ្រង់ ហើយថាខ្ញុំនឹងត្រូវបានប្រទានពរដោយការបំរើរបស់ពួកគាត់ និងចំពោះការគាំទ្រដល់ពួកគាត់។

ខ្ញុំបានមើលឃើញថា អស់រយៈពេលជាច្រើនថ្ងៃ និងខែបន្ទាប់ពីការគាំទ្រដល់ពួកគេមក ប្រធានស្តេកទាំងនោះត្រូវបានតំកើងនៅក្នុងការហៅរបស់ពួកគេ។ ខ្ញុំបានឃើញអព្ភូតហេតុដូចគ្នានេះនៅក្នុងការបំរើរបស់ប្រធាន ម៉នសុន នៅពេលលោកបានទទួលការហៅឱ្យធ្វើជាអធិបតីក្នុងនាមជាព្យាការី និងប្រធាននៃសាសនាចក្រ ហើយដើម្បីអនុវត្តកូនសោទាំងអស់នៃបព្វជិតភាពនៅលើផែនដី។ វិវរណៈ និងការបំផុសគំនិត បានកើតឡើង ចំពោះលោកនៅក្នុងវត្តមានរបស់ខ្ញុំ ដែលបញ្ជាក់ដល់ខ្ញុំថា ព្រះកំពុងតែគោរពដល់កូនសោទាំងនោះ។ ខ្ញុំគឺជាសាក្សីមួយរូប។ កូនសោទាំងនោះគឺជាកូនសោ បព្វជិតភាព ដែលនៅក្នុងព្រះបន្ទូលរបស់ព្រះអម្ចាស់ប្រាប់ថា "ដែលគ្មានការចាប់ផ្តើម និងទីបញ្ចប់ឡើយ"។4

ខ្ញុំថ្លែងជាសាក្សីដ៏ឧឡារិកចំពោះអ្នករាល់គ្នាថានេះគឺជាសាសនាចក្រពិត និងសកម្មរបស់ព្រះយេស៊ូវគ្រីស្ទ។ ព្រះវរបិតាសួគ៌នឹងឆ្លើយតបនូវការអធិស្ឋានដោយស្មោះរបស់អ្នកដើម្បីដឹងដោយផ្ទាល់ខ្លួន។ អ្នកអាចមានសាក្សីមួយថាការហៅដែលអ្នកបានគាំទ្រនៅថ្ងៃនេះ គឺមកពីព្រះ។ បន្ថែមពីនោះទៀត អ្នកអាចដឹងថានៅក្នុងសាសនាចក្រនេះពិធីបរិសុទ្ធទាំងឡាយដែលត្រូវបានធ្វើឡើង អាចសំអាតព្រលឹង និងអាចចងនៅផែនដី ហើយនៅស្ថានសួគ៌ ដូចជានៅក្នុងជំនាន់របស់ពេត្រុស យ៉ាកុប និងយ៉ូហាន។ កូនសោ និងពិធីបរិសុទ្ធទាំងនោះ ឥឡូវត្រូវបានស្តារឡើងវិញនៅក្នុងភាពពេញលេញ តាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ ហើយបានប្រគល់បន្តឱ្យអ្នកស្នងរបស់លោក។ ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ។ ទ្រង់មានព្រះជន្មរស់។ ខ្ញុំដឹងយ៉ាងពិតប្រាកដ។ ខ្ញុំធ្វើទីបន្ទាល់ថា ថូម៉ាស អេស ម៉នសុន គឺជាព្យាការីនៅរស់របស់ទ្រង់។ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយពិត ហើយនៅសកម្ម។ ខ្ញុំសូមធ្វើទីបន្ទាល់ដូច្នេះ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. គ និង ស 1:30--33 ។
2. សូមមើល គ និង ស 130:2 ។
3. ហេលេមិន 5:18 ។
4. សូមមើល *ប្រវត្តិសាស្ត្រសាសនាចក្រ* 4:227 ។
5. អាលម៉ា 13:8 ។